**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ៤០១៨ ព.ណ.រ.ផ.ផ

ថ្ងៃព្រហស្បតិ៍ ៧កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៥

# សេចក្តីជូនដំណឹង

## ស្តីពី

## ជំនួបពាណិជ្ជកម្ម "កាលានុវត្តភាពនៃទីផ្សារផលិតផលកម្ពុជាក្នុងយុគសម័យថ្មី"

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនអំពីការរៀបចំជំនួបពាណិជ្ជកម្មស្តីពី **"កាលានុវត្តភាពនៃទីផ្សារផលិតផលកម្ពុជាក្នុងយុគសម័យថ្មី"** នាអំឡុងពិព័រណ៍ពាណិជ្ជកម្មកម្ពុជា **លើកទី១៨** ដែលនឹងប្រព្រឹត្តទៅនៅ**ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៥ វេលាម៉ោង១៣:៣០នាទី** នៅ**សាលសន្និបាតកោះពេជ្រ ហ្វ្រេនហល បុរីប៉េងហួត បឹងស្នោ រាជធានីភ្នំពេញ**។

ជំនួបពាណិជ្ជកម្មនេះ រៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយ និងជំរុញការលក់និងប្រើប្រាស់ផលិតផលខ្មែរឱ្យកាន់តែទូលំទូលាយ តាមរយៈការស្វែងយល់អំពីការអភិវឌ្ឍផលិតផលរបស់សិប្បកម្ម សហគ្រាសធុនតូច និងមធ្យមកម្ពុជា និងផ្តល់ឱកាសសម្រាប់ផ្សារភ្ជាប់ទំនាក់ទំនងធុរកិច្ចរវាងអ្នកផលិត អ្នកផ្គត់ផ្គង់ និងអ្នកបញ្ជាទិញ ស្របតាមនិន្នាការទីផ្សារបច្ចុប្បន្ន។ នាអំឡុងពេលនៃការរៀបចំជំនួបពាណិជ្ជកម្មនេះ មានការតាំងបង្ហាញផលិតផលសក្តានុពលកម្ពុជាដូចជា អង្ករ ស្វាយចន្ទី ម្រេច ចេកអំបូងលឿង មៀនប៉ៃលិន ស្វាយផ្លូង ទឹកឃ្មុំ និងអំបិល រួមទាំងផលិតផលសំខាន់ផ្សេងៗទៀតរបស់កម្ពុជា នៅក្នុងពិព័រណ៍ពាណិជ្ជកម្មកម្ពុជា ដែលនឹងទាក់ទាញវិនិយោគិន ធុរជន ពាណិជ្ជករ និងភ្ញៀវទេសចរណ៍មកកាន់កម្ពុជាបន្ថែមទៀត។

ក្នុងន័យនេះ ក្រសួងពាណិជ្ជកម្ម សូមអញ្ជើញ **ភ្ញៀវជាតិ និងអន្តរជាតិ លោក-លោកស្រី ដែលជាពាណិជ្ជករ ផលិតករ វិនិយោគិន និងសាធារណជន** ដែលមានបំណងចូលរួមកម្មវិធីនេះ សូមធ្វើការទាក់ទងមកកាន់នាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារ ឱ្យបានត្រឹមថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៥ ជាកំណត់។ ចំពោះវត្តមានចូលរួមរបស់ **ភ្ញៀវជាតិ និងអន្តរជាតិ លោក-លោកស្រី ដែលជាពាណិជ្ជករ ផលិតករ វិនិយោគិន និងសាធារណជន** ពិតជាមានតម្លៃមិនអាចកាត់ថ្លៃបានសម្រាប់ព្រឹត្តិការណ៍នេះ និងជួយជំរុញសក្តានុពលបន្ថែមសម្រាប់ការធ្វើអាជីវកម្មនៅកម្ពុជា។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងនាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារ នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម តាមរយៈលេខទូរស័ព្ទ ឬតេលេក្រាម៖ +៨៥៥ ១៧ ៣២២ ១១២/+៨៥៥ ៧៧ ៣៣៤ ២៥៥/ +៨៥៥ ៧៨ ៦៥៦ ៥០៨។

**សូមអរគុណ!**

https://go.gov.kh/moc/...

GO.gov.KH

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩

Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469